**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០៩៧ សណ.អគ

ថ្ងៃអាទិត្យ ១០កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**
**និងជាប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់រាជធានី ខេត្ត**

**កម្មវត្ថុ៖** បន្តជម្រុញការអនុវត្តគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងរាជធានី ខេត្ត។

**យោង៖** សារាចរណែនាំលេខ ០០៤ សរណន. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ក្នុងដំណាក់កាលទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ (COVID-19)

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់រាជធានី ខេត្ត** ឱ្យបានជ្រាបថា ដោយអនុវត្តតាមការណែនាំជាមួយរាជរដ្ឋាភិបាល និងគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19) ក្រសួងទេសចរណ៍ សូមក្រើនរំលឹក **ឯកឧត្តម លោកជំទាវ** ឱ្យបន្តយកចិត្តទុកដាក់ពង្រឹងការអនុវត្តជាប្រចាំនូវគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងរាជធានី ខេត្ត ដែលក្នុងនោះរួមមាន៖

១). ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យបានជាប្រចាំនូវអនុសាសន៍ណែនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នូវវិធានការណ៍ **"៣ ការពារ ៣ កុំ"** ដែលរួមមាន៖

- អនុវត្ត ៣ ការពារ
  - ពាក់ម៉ាស់
  - លាងដៃឱ្យបានញឹកញាប់
  - គម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល ដោយចាប់ពី ១ម៉ែតកន្លះឡើងទៅឱ្យបានគ្រប់គ្នា និងនៅគ្រប់ទីកន្លែង។
- អនុវត្ត ៣ កុំ
  - កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក រកកន្លែងមានខ្យល់ចេញចូលល្អ
  - កុំទៅកន្លែងមនុស្សច្រើនកុះករ
  - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបគ្នាជាដើម ពេលជួបគ្នា អ្នកមានផ្តាសាយ ឬសង្ស័យមានជំងឺកូវីដ១៩ កុំចេញក្រៅ ហើយត្រូវទាក់ទងទៅគ្រូពេទ្យ ឬហៅទៅលេខ ១១៥។

២). បន្តត្រួតពិនិត្យជាប្រចាំ និងពង្រឹងការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាលចំពោះអាជីវកម្មស្ប៉ាម៉ាស្សាសុខភាព និងអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (មានខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀរហ្គាឌិន) ដែលពុំទាន់បានអនុញ្ញាតឱ្យបើកដំណើរឡើងវិញ។

វិមានលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

៣). ចំពោះអាជីវកម្មក្លឹបកម្សាន្ត និងខារ៉ាអូខេKTV នៅរាជធានីភ្នំពេញ និងនៅតាមបណ្ដាខេត្ត ដែលបានប្រែក្លាយទៅជាភោជនីយដ្ឋាន ត្រូវគោរពឱ្យបានម៉ឺងម៉ាត់នូវវិធាននៃក្រសួងសុខាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។ ក្នុងករណីដែលអាជីវកម្មធ្វេសប្រហែស មិនបានអនុវត្តនូវផ្នែក ឬចំណុចណាមួយនៃគោលការណ៍ណែនាំ ត្រូវផ្អាកសកម្មភាពអាជីវកម្មរហូតមានការកែតម្រូវស្របតាមគោលការណ៍ណែនាំ ទើបត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម។

៤). ចំពោះវិធានសុវត្ថិភាពទេសចរណ៍ (ជំហានទី១) ដែលបានដាក់ចេញឱ្យអនុវត្តកន្លងមក ក្នុងនោះរួមមាន វិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មស្នាក់នៅទេសចរណ៍ វិធានសុវត្ថិភាពសម្រាប់សេវាកម្មភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍ វិធានសុវត្ថិភាពសម្រាប់សេវាកម្មដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក វិធានសុវត្ថិភាពសម្រាប់សេវាកម្មដឹកជញ្ជូនទេសចរណ៍ផ្លូវគោក វិធានសុវត្ថិភាពសម្រាប់រមណីយដ្ឋានទេសចរណ៍ និងវិធានសុវត្ថិភាពសម្រាប់សហគមន៍ទេសចរណ៍ ត្រូវបន្តយកចិត្តទុកដាក់ផ្សព្វផ្សាយឱ្យកាន់តែផុលផុស និងអនុវត្តឱ្យបានជាប្រចាំជាងមុនបន្ថែមទៀត តាមរយៈក្រុមការងារបានបង្កើតឡើង។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាពិនិត្យ និងចាត់ចែងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់រាជធានី ខេត្ត** ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ